# ក្រសួងមុខងារសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

## សមិទ្ធផលសំខាន់ៗក្នុងវិស័យមុខងារសាធារណៈ (១៩៩៨-២០១៨) ក្រោយការអនុវត្តគោលនយោបាយឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាល

ដោយអនុវត្តតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** វិស័យមុខងារសាធារណៈក្រោមការដឹកនាំអនុវត្តផ្ទាល់របស់ឯកឧត្តម កិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** និងថ្នាក់ដឹកនាំដទៃទៀត សម្រេចបាននូវសមិទ្ធផលសំខាន់ៗមានជាអាទិ៍៖

- បានបើកផ្តល់បៀវត្សប្រចាំខែជូនមន្ត្រីរាជការ បានយ៉ាងទៀងទាត់ជារៀងរាល់ខែតាមប្រព័ន្ធធនាគារ ជាពិសេសកំពុងឈានទៅរកការបើកផ្តល់បៀវត្សចំនួន២ដងក្នុងមួយខែចាប់ពីឆ្នាំ២០១៩ នេះតទៅ។
- ប្រាក់បៀវត្សមន្ត្រីរាជការមានការកើនឡើងជាលំដាប់ បច្ចុប្បន្នប្រាក់បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិល ក្នុងវិស័យរដ្ឋបាល **១,០១៤,៤៥០រៀល** វិស័យអប់រំ**១,១១៤,៤៥០រៀល** និងវិស័យសុខាភិបាល**១,១១៤,៤៥០រៀល** ព្រមទាំងបន្តកើនឡើងនៅឆ្នាំ២០១៩ ដោយតម្លៃឯកតាសន្ទស្សន៍ប្រាក់បៀវត្សមូលដ្ឋាននឹងឡើងដល់ **២៣៤០រៀល/សន្ទស្សន៍**។
- បានធ្វើនិយ័តកម្មជូនមន្ត្រីរាជការស៊ីវិលដែលខកខានមិនបានឡើងថ្នាក់ និងឋានន្តរស័ក្តិ ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០១៤ ក្នុងនោះការដំឡើងថ្នាក់ ចំនួន**១៥៦.៥៣៦**នាក់ និង ការដំឡើងឋានន្តរស័ក្តិចំនួន**៣.៩០៤**នាក់។
- បានពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ចាប់តាំងពីការកត់ត្រាដោយដៃរហូតមានការគ្រប់គ្រងតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ ក្របខណ្ឌមន្ត្រីរាជការ ដំឡើងប្រាក់បំណាច់មុខងារ ដំឡើងប្រាក់បៀវត្សមូលដ្ឋាន និង ផ្តល់ប្រាក់វិភាជន៍គ្រួសារ ក្នុងទិសដៅពង្រឹងប្រសិទ្ធភាពការងារ បង្កើនផលិតភាព និងលើកកម្ពស់ជីវភាព មន្ត្រីរាជការ។
- បានចូលរួមសហការរៀបចំរបបសន្តិសុខសង្គម(ប.ស.ស)សម្រាប់មន្ត្រីរាជការស៊ីវិល។
- បានកសាងនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីបម្រើដល់ការងារគ្រប់គ្រងមន្ត្រីរាជការ ការអភិវឌ្ឍវិស័យមុខងារសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ការកែលម្អនិងពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ។
- បានរៀបចំនិងដាក់ឱ្យអនុវត្ត (ក)គោលនយោបាយ ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ខ)ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និង (គ)អនុក្រឹត្យនិងសេចក្តីណែនាំ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង និងការបញ្ចប់មុខតំណែង របស់មន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
- សាលាភូមិន្ទរដ្ឋបាល បានធ្វើការបណ្តុះបណ្តាលសិស្សមន្ត្រីនិងមន្ត្រីរាជការរហូតមកដល់ឆ្នាំ២០១៨នេះ៖ បានចំនួនសរុប**៩.២៤៣**នាក់ ដោយសហការជាមួយក្រសួង ស្ថាប័ននានា តាមរយៈ អនុស្សរណៈនៃការយោគយល់ (MOU)។
- ការវិវត្តន៍របស់វិស័យមុខងារសាធារណៈកម្ពុជាបានឈានចូលទៅក្នុងកិច្ចសហប្រតិបត្តិការមុខងារសាធារណៈអាស៊ានពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ននេះ មានការរីកចម្រើនខ្លាំងឡើងៗ ដោយមានការទទួលស្គាល់ពីប្រទេសក្នុងតំបន់និងអន្តរជាតិ ហើយកម្ពុជាធ្លាប់បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈនៅឆ្នាំ២០០៥ និង២០០៦។

ផ្អែកលើលទ្ធផលការងារដែលសម្រេចបានយ៉ាងច្រើនពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ក្រសួងមុខងារសាធារណៈបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាឱ្យទទួលបាននូវជំនឿទុកចិត្តពីសំណាក់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ក៏ដូចជាប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។

ថ្ងៃ សុក្រ ៦ កើត ខែ បិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៥ ឆ្នាំ២០១៨

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

# ក្រសួងមុខងារសាធារណៈ

# បាវចនាក្រសួងមុខងារសាធារណៈ



## ១. ដំណើរការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ

- ១ ក្រសួងមុខងារសាធារណៈជូនដំណឹងទៅគ្រប់ក្រសួង ស្ថាប័នដើម្បីរៀបចំផែនការឆ្នាំបន្ទាប់
- ២ ក្រសួង ស្ថាប័នបញ្ជូនផែនការមកក្រសួងមុខងារសាធារណៈវិញ
- ៣ ក្រសួងមុខងារសាធារណៈដឹកនាំកិច្ចប្រជុំចង្អៀតជាមួយក្រសួង ស្ថាប័ន
- ៤ ក្រសួងមុខងារសាធារណៈរៀបចំប្រជុំអន្តរក្រសួងដើម្បីសម្រេចផែនការប្រចាំឆ្នាំ
- ៥ ក្រសួងមុខងារសាធារណៈបូកសរុបផែនការក្របខណ្ឌទូទាំងប្រទេស
- ៦ រាជរដ្ឋាភិបាលអនុម័តលើផែនការក្របខណ្ឌសរុប
- ៧ ក្រសួងមុខងារសាធារណៈជូនដំណឹងស្តីពីការបែងចែកផែនការក្របខណ្ឌទៅក្រសួង ស្ថាប័ន
- ៨ ក្រសួង ស្ថាប័នរៀបចំប្រឡងជ្រើសរើសក្របខណ្ឌ

## ២. ដំណើរការបញ្ចូលក្របខណ្ឌ និងរៀបចំបៀវត្សមន្ត្រីរាជការ

### ២.១. តាមរយៈក្រសួង ស្ថាប័ន

- ១ ផែនការក្របខណ្ឌប្រចាំឆ្នាំ
- ២ ការប្រកាសជ្រើសរើសតាមក្រសួង ស្ថាប័ន
- ៣ ការដាក់ពាក្យសុំសិទ្ធិប្រឡង
- ៤ ការប្រឡងប្រជែងចូលក្របខណ្ឌមន្ត្រីរាជការ
- ៥ ការប្រកាសលទ្ធផលប្រឡង
- ៦ ការបង្ហាញខ្លួន និងបំពេញសលាកបត្រព័ត៌មាន
- ៧ ការចូលបំពេញកម្មសិក្សា១២ខែ និងទទួលបៀវត្សតាមប្រភេទក្របខណ្ឌ ក.៣.៤/ខ.៣.៤/គ.១០
- ៨ ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល

### ២.២. តាមរយៈសាលាភូមិន្ទរដ្ឋបាល

1. ទទួលចំនួនក្របខណ្ឌពីប្រមុខរាជរដ្ឋាភិបាល
2. ប្រកាសជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការ
3. បេក្ខជនដាក់ពាក្យសុំសិទ្ធិប្រឡងតាម Online
4. ការប្រឡងប្រជែង/សម្ភាសន៍
5. ការប្រកាសលទ្ធផលប្រឡង
6. ការបណ្ដុះបណ្ដាលតាមឆ្នាំសិក្សា
7. ពីរឆ្នាំសម្រាប់សិស្សមន្ត្រីជាន់ខ្ពស់ និងមួយឆ្នាំសម្រាប់សិស្សមន្ត្រីក្រមការ
8. ជ្រើសរើសក្រសួង ស្ថាប័នដើម្បីបំពេញការងារ
9. ការចូលបំពេញកម្មសិក្សា១២ខែ និង ទទួលបៀវត្សតាមប្រភេទក្របខណ្ឌ ក.៣.១ / ខ.៣.១
10. ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល

## ៣. លក្ខខណ្ឌជ្រើសរើសមន្ត្រីរាជការស៊ីវិល

### ៣.១. តាមរយៈក្រសួង ស្ថាប័ន

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ
- ក្របខណ្ឌ "គ" បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬចំណេះបច្ចេកទេស ឬចំណេះធ្វើការងារជាក់លាក់ និងត្រូវមានអាយុច្រើនបំផុត២៥ឆ្នាំ
- ក្របខណ្ឌ "ខ" បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្ររង ឬសមមូល ត្រូវមានអាយុច្រើនបំផុត២៨ឆ្នាំ
- ក្របខណ្ឌ "ក" មានលក្ខខណ្ឌដូចខាងក្រោម៖
  - បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសមមូល និងត្រូវមានអាយុច្រើនបំផុត៣៥ឆ្នាំ
  - បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូលនិងត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ
  - បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ត្រូវបានលើកលែងអាយុ
- បេក្ខជនជាមន្ត្រីរាជការដែលទទួលបានការតែងតាំងស៊ប់រួចហើយត្រូវបានលើកលែងអាយុ
- បេក្ខជនសម្រាប់មុខតំណែងវិជ្ជាជីវៈសុខាភិបាលត្រូវបានលើកលែងអាយុ
- ត្រូវមានសញ្ញាបត្រនិងជំនាញសមមូលនឹងលក្ខខណ្ឌជ្រើសរើស
- ត្រូវមានលិខិតបញ្ជាក់កិរិយាមាយាទ
- ត្រូវមានលិខិតថ្កោលទោស
- ត្រូវមានលិខិតបញ្ជាក់សុខភាពសមស្របនឹងលក្ខខណ្ឌការងារ
- ជនជាតិភាគតិច អ្នករស់នៅតំបន់ដាច់ស្រយាល ស្ត្រី និងជនពិការត្រូវបានផ្ដល់អាទិភាព។

### ៣.២. តាមរយៈសាលាភូមិន្ទរដ្ឋបាល

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ
- សិស្សមន្ត្រីក្រមការ(ប្រភេទក្របខណ្ឌ "ខ") ជាបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្ររង ឬ សមមូលត្រូវមានអាយុច្រើនបំផុត២៨ឆ្នាំ
- សិស្សមន្ត្រីជាន់ខ្ពស់(ប្រភេទក្របខណ្ឌ "ក") មានលក្ខខណ្ឌដូចខាងក្រោម៖
  - បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
  - បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ
  - បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ត្រូវបានលើកលែងអាយុ
- ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ក្រោយពេលប្រឡងជាប់ជាស្ថាពរ
- ត្រូវមានលិខិតបញ្ជាក់សុខភាព ចេញដោយនាយកដ្ឋានពេទ្យការងារក្រោយពេលប្រឡងជាប់ជាស្ថាពរ។

## ៤. តារាងប្រាក់បៀវត្សអប្បបរមា







បៀវត្សអប្បបរមាវិស័យសុខាភិបាល
1,400,000
1,200,000
1,000,000
800,000
600,000
400,000
200,000
-
144,500
111,000
85,000
300,400
184,000
130,000
589,400
386,400
360,000
1,304,850
1,199,000
1,114,450
2003
2008
2013
2018
ក.៣.៤
ខ.៣.៤
គ.១០


ការដំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន( គិតជារៀល )
2,500
2,000
1,500
1,000
500
-
300
345
600
1,520
2,130
២០០២
២០០៥
២០០៨
២០១៣
២០១៨

# ៥. ការគណនាបៀវត្សសរុបមន្ត្រីរាជការស៊ីវិល និងការគណនាពន្ធលើបៀវត្ស

## តារាងបៀវត្សមូលដ្ឋានមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៨

| ប្រភេទក្របខណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | 3 | | | | 2 | | | | 1 | | | | | |
| | ថ្នាក់ | | | | | | | | | | | | | |
| | 4 | 3 | 2 | 1 | 4 | 3 | 2 | 1 | 6 | 5 | 4 | 3 | 2 | 1 |
| | កម្រិតសន្ទស្សន៍ | | | | | | | | | | | | | |
| | 345 | 354 | 364 | 379 | 394 | 410 | 426 | 443 | 461 | 479 | 496 | 513 | 531 | 550 |
| | បៀវត្សមូលដ្ឋានតាមក្របខណ្ឌ-ឋានន្តរស័ក្តិនិងថ្នាក់ | | | | | | | | | | | | | |
| | 734,850 | 754,020 | 775,320 | 807,270 | 839,220 | 873,300 | 907,380 | 943,590 | 981,930 | 1,020,270 | 1,056,480 | 1,092,690 | 1,131,030 | 1,171,500 |

| ប្រភេទក្របខណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ | 3 | | | | 2 | | | | 1 | | | | | |
| | ថ្នាក់ | | | | | | | | | | | | | |
| | 4 | 3 | 2 | 1 | 4 | 3 | 2 | 1 | 6 | 5 | 4 | 3 | 2 | 1 |
| | កម្រិតសន្ទស្សន៍ | | | | | | | | | | | | | |
| | 300 | 308 | 318 | 331 | 344 | 358 | 369 | 380 | 393 | 407 | 421 | 436 | 453 | 470 |
| | បៀវត្សមូលដ្ឋានតាមក្របខណ្ឌ-ឋានន្តរស័ក្តិនិងថ្នាក់ | | | | | | | | | | | | | |
| | 639,000 | 656,040 | 677,340 | 705,030 | 732,720 | 762,540 | 785,970 | 809,400 | 837,090 | 866,910 | 896,730 | 928,680 | 964,890 | 1,001,100 |

| ប្រភេទក្របខណ្ឌ | ថ្នាក់ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| គ | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 |
| | កម្រិតសន្ទស្សន៍ | | | | | | | | | |
| | 265 | 274 | 284 | 295 | 307 | 321 | 335 | 352 | 370 | 390 |
| | បៀវត្សមូលដ្ឋានតាមក្របខណ្ឌ-ឋានន្តរស័ក្តិនិងថ្នាក់ | | | | | | | | | |
| | 564,450 | 583,620 | 604,920 | 628,350 | 653,910 | 683,730 | 713,550 | 749,760 | 788,100 | 830,700 |

- តំលៃឯកតាសន្ទស្សន៍ = ២១៣០
- បៀវត្សមូលដ្ឋាន = សន្ទស្សន៍បៀវត្ស x តំលៃសន្ទស្សន៍

# ៦. ការគណនាបៀវត្សសរុបមន្ត្រីរាជការស៊ីវិល និងការគណនាពន្ធលើបៀវត្ស

## ការគណនាបៀវត្សសរុបមន្ត្រីរាជការស៊ីវិល

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បៀវត្សសរុប | = | បៀវត្សមូលដ្ឋាន | + | ប្រាក់បំណាច់មុខងារ ឬបន្ថែម | + | ហានិភ័យ (តំបន់-សុខភាព) | + | ប្រាក់វិភាជន៍គ្រួសារ (សហព័ទ្ធ-កូន) | + | ប្រាក់បង្រៀនពីរវេន ឬគួប (វិស័យអប់រំ) |

ឧទាហរណ៍៖ លោក ក មានក្របខណ្ឌ គ.៩ ជាគ្រូបង្រៀនកម្រិតបឋមទទួលបានប្រាក់ហានិភ័យតំបន់ ប្រាក់វិភាជន៍គ្រួសារប្រពន្ធ និងកូនចំនួន ០២នាក់។

ការគណនា៖

| | | បៀវត្សមូលដ្ឋាន | | បំណាច់មុខងារ | | ប្រាក់តំបន់ | | វិភាជន៍គ្រួសារ | | សរុបបៀវត្ស |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | 15,000 | | |
| បៀវត្សសរុប | = | 583,620 | + | 550,000 | + | 80,000 | + | 10,000 | = | 1,248,620 |
| | | | | | | | | 10,000 | | |

## ការគណនាពន្ធលើបៀវត្ស

ប្រាក់ពន្ធលើបៀវត្ស = បៀវត្សជាប់ពន្ធ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធ

បៀវត្សជាប់ពន្ធ = បៀវត្សសរុប - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុកពន្ធលើប្រាក់បៀវត្ស

ឧទាហរណ៍៖ ករណីនៅលីវ

| | | បៀវត្សមូលដ្ឋាន | | បំណាច់មុខងារ | | ប្រាក់តំបន់ | | វិភាជន៍គ្រួសារ | | សរុបបៀវត្ស |
|---|---|---|---|---|---|---|---|---|---|---|
| បៀវត្សសរុប | = | 583,620 | + | 550,000 | + | 80,000 | + | 0 | = | 1,213,620 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បៀវត្សជាប់ពន្ធ | = | 1,213,620 | - | 0 | = | 1,213,620 | | |
| ប្រាក់ពន្ធលើបៀវត្ស | = | (1213620 | x | 0.05) | - | 60,000 | = | 681 |

ករណីមានប្រពន្ធ និងកូនចំនួន ០២នាក់

| | | បៀវត្សមូលដ្ឋាន | | បំណាច់មុខងារ | | ប្រាក់តំបន់ | | វិភាជន៍គ្រួសារ | | សរុបបៀវត្ស |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | 15,000 | | |
| បៀវត្សសរុប | = | 583,620 | + | 550,000 | + | 80,000 | + | 10,000 | = | 1,248,620 |
| | | | | | | | | 10,000 | | |

| | | | | |
|---|---|---|---|---|
| បៀវត្សជាប់ពន្ធ | = | 1,248,620 | - (150,000 x 3) = | 798,620 |
| ប្រាក់ពន្ធលើបៀវត្ស | = | 0 | | |

សេចក្ដីណែនាំស្ដីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០២ សហវ.អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨។

# ៧. ផែនការក្របខណ្ឌឆ្នាំ២០១៨ តាមក្រសួង ស្ថាប័ន

| ល.រ | ក្រសួង ស្ថាប័ន | ចំនួនក្របខណ្ឌឆ្នាំ២០១៨ |
|---|---|---|
| ១ | ព្រះបរមរាជវាំង | ០ |
| ២ | ទីស្តីការគណរដ្ឋមន្ត្រី | ១៦ |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ២០ |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០ |
| ៥ | មហាផ្ទៃ | ៣៥៣ |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ០ |
| ៧ | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១៥ |
| ៨ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០ |
| ៩ | ព័ត៌មាន | ០ |
| ១០ | សុខាភិបាល | ៧០០ |
| ១១ | រ៉ែ និងថាមពល | ១១ |
| ១២ | ផែនការ | ០ |
| ១៣ | ពាណិជ្ជកម្ម | ២០ |
| ១៤ | អប់រំយុវជន និងកីឡា | ៣៦០០ |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤០ |
| ១៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ៣០ |
| ១៧ | បរិស្ថាន | ១៨ |
| ១៨ | អភិវឌ្ឍន៍ជនបទ | ២០ |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០ |
| ២០ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | ២០ |
| ២១ | ធម្មការ និងសាសនា | ០ |
| ២២ | កិច្ចការនារី | ២០ |
| ២៣ | សាធារណការ និងដឹកជញ្ជូន | ៥០ |
| ២៤ | យុត្តិធម៌ | ១ |
| ២៥ | ទេសចរណ៍ | ១៥ |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០ |
| ២៧ | ធនធានទឹក និងឧតុនិយម | ២០ |
| ២៨ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៤ |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ១ |
| ៣០ | មុខងារសាធារណៈ | ៥ |
| ៣១ | ឧស្សាហកម្ម និងសិប្បកម្ម | ២០ |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើភារវកម្ម | ០ |
| **សរុប** | | **៥០,២៩** |

## ៨. ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ក្រោមជាតិតាមក្រសួង ស្ថាប័នឆ្នាំ២០១៨

| ល.រ | ក្រសួង ស្ថាប័ន | ថ្នាក់ជាតិ | ថ្នាក់ក្រោមជាតិ | សរុប |
|---|---|---|---|---|
| ១ | ព្រះបរមរាជវាំង | ៣៧៨ | | ៣៧៨ |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១៥៧៨ | | ១៥៧៨ |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៧២៥ | | ៧២៥ |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១០២ | | ១០២ |
| ៥ | មហាផ្ទៃ | ២១៩៤ | ១១០៣៦ | ១៣២៣០ |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច | ៤៤៨ | ៣៤១ | ៧៨៩ |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ៦៤១ | | ៦៤១ |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៥៤១០ | ៦២៧ | ៦០៣៧ |
| ៩ | ព័ត៌មាន | ១០៦៥ | ៧០០ | ១៧៦៥ |
| ១០ | សុខាភិបាល | ៥៧៩២ | ១៩៤៩៧ | ២៥២៨៩ |
| ១១ | រ៉ែនិងថាមពល | ៤៧៧ | ៣៨៤ | ៨៦១ |
| ១២ | ផែនការ | ១០០១ | ១៨៤៥ | ២៨៤៦ |
| ១៣ | ពាណិជ្ជកម្ម | ១៣២៥ | ៤៨៦ | ១៨១១ |
| ១៤ | អប់រំ យុវជននិងកីឡា | ៣៦៧៦ | ១១៦៦៣៦ | ១២០៣១២ |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ២៩៣៤ | ៣៩៥៦ | ៦៨៩០ |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ១៤៨៨ | ៩៧៧ | ២៤៦៥ |
| ១៧ | បរិស្ថាន | ៨៧៦ | ១៩៦៤ | ២៨៤០ |
| ១៨ | អភិវឌ្ឍន៍ជនបទ | ៦២៧ | ១១៨៤ | ១៨១១ |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៨២២ | ១៣០០ | ២១២២ |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ៧៧០ | ៤៨២ | ១២៥២ |
| ២១ | ធម្មការនិងសាសនា | ៤៨៦ | ១០៦២ | ១៥៤៨ |
| ២២ | កិច្ចការនារី | ២៦៣ | ៧៥១ | ១០១៤ |
| ២៣ | សាធារណៈការនិងដឹកជញ្ជូន | ១៥២៦ | ១៩៨២ | ៣៥០៨ |
| ២៤ | យុត្តិធម៌ | ៥៩០ | ៥៧៨ | ១១៦៨ |
| ២៥ | ទេសចរណ៍ | ៦២៦ | ៥៦៤ | ១១៩០ |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៧៥៩ | ២៤៧៩ | ៣២៣៨ |
| ២៧ | ធនធានទឹក និងឧតុនិយម | ៩១៨ | ៥៩១ | ១៥០៩ |
| ២៨ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៨៧៣ | ១៥២៤ | ៤៣៩៧ |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ៤១៥ | | ៤១៥ |
| ៣០ | មុខងារសាធារណៈ | ៤៩៦ | ៣២៤ | ៨២០ |
| ៣១ | ឧស្សាហកម្ម និងសិប្បកម្ម | ៥៩៨ | ៥៣៦ | ១១៣៤ |
| ៣២ | គណៈកម្មការជាតិប្រឆាំងអំពើភារវកម្ម | ២៨៣ | | ២៨៣ |
| | **សរុបរួម** | **៤២១៦២** | **១៧១៨០៦** | **២១៣៩៦៨** |

## ចំនួនមន្ត្រីរាជការស៊ីវិលជាបុរសនិងស្ត្រី តាមប្រភេទក្របខណ្ឌ

| ក្របខណ្ឌ | ថ្នាក់ជាតិ | | | ថ្នាក់ក្រោមជាតិ | | | សរុបរួម |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | |
| **ក** | 18,999 | 6,786 | 25,785 | 22,276 | 8,878 | 31,154 | **56,939** |
| **ខ** | 4,196 | 2,943 | 7,139 | 36,494 | 25,632 | 62,126 | **69,265** |
| **គ** | 2,536 | 1,606 | 4,142 | 37,210 | 38,416 | 75,626 | **79,768** |
| **សរុប** | 25,731 | 11,335 | 37,066 | 95,980 | 72,926 | 168,906 | **205,972** |

## ៩. ការវិវឌ្ឍអាជីពមន្ត្រីរាជការស៊ីវិល



## ១០. ការអនុវត្តការងារក្របខណ្ឌវិស័យមុខងារសាធារណៈអាស៊ាន

ក្រសួងមុខងារសាធារណៈ បានចូលរួមអនុវត្តការងារមុខងារសាធារណៈអាស៊ានតាមរយៈយន្តការនៃកិច្ចសហប្រតិបត្តិការអាស៊ានស្តីពីវិស័យមុខងារសាធារណៈដើម្បីកសាងនិងធ្វើឱ្យមាននិរន្តភាពនូវវិស័យមុខងារសាធារណៈអាស៊ាន ប្រកបដោយគុណភាពខ្ពស់ដើម្បីបម្រើផលប្រយោជន៍ប្រជាជនអាស៊ាន និងឈានទៅសម្រេចបាននូវចក្ខុវិស័យអាស៊ាន ឆ្នាំ ២០២៥ ។ សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងរយៈពេល ១០ ឆ្នាំរួមមាន៖

- បានរៀបចំ និងចូលរួមផ្តល់យោបល់ និងអនុវត្តលិខិតូបករណ៍អាស៊ានពាក់ព័ន្ធវិស័យមុខងារសាធារណៈ អាស៊ាន ដើម្បីឈានទៅសម្រេចការកសាងសហគមន៍អាស៊ាន។
- បានអភិវឌ្ឍន៍សមត្ថភាពមូលធនមនុស្សនិងស្ថាប័ននៃក្រសួងមុខងារសាធារណៈតាមរយៈកាបញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីចូលរួមក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យមុខងារសាធារណៈអាស៊ាន និងទ្វេភាគីជាមួយបណ្តាប្រទេសដៃគូ អង្គការដទៃផ្សេងៗទៀត រួមមាន៖ ប្រទេស អូស្ត្រាលី Azerbaijan ឥណ្ឌា ឥណ្ឌូនេស៊ី អាឡឺម៉ង់ ហូឡង់ ជប៉ុន កាហ្សាក់ស្ថាន កូរ៉េ ម៉ារុក ណូវែលហ្សេឡង់ សិង្ហបុរី ស្រីលង្កា ថៃ ម៉ាលេស៊ី ហ្វីលីពីន ប៊្រុយណេ-ដារ៉ូសាឡឹម កាតា វៀតណាម អង្គការសហប្រជាជាតិ United Arab Emirates USA JICA និង KOICA ដើម្បីគាំទ្រការអភិវឌ្ឍន៍ វិស័យមុខងារសាធារណៈកម្ពុជា និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងការកសាងសហគមន៍អាស៊ាន ឆ្នាំ ២០២៥ ។
- បានលើកកម្ពស់ការយល់ដឹងពីអាស៊ាន និង ACCSM ( Asean Cooperation for Civil Service Matters ) ដល់មន្ត្រីរាជការនិងអនុវត្តគម្រោងនានា របស់អាស៊ានដែលរៀបចំដោយក្រសួងមុខងារសាធារណៈរួមមាន៖
    - a. សិក្ខាសាលាស្តីពីក្របខណ្ឌសមត្ថភាព និងការគ្រប់គ្រងគុណផលការងារដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅខេត្តសៀមរាប
    - b. គម្រោងសេចក្តីណែនាំអាស៊ានស្តីពីការផ្តល់សេវាសាធារណៈ និងរៀបចំគម្រោងបង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលASEAN+3 Center for Civil Service Research and Innovation ។
    - c. បានសម្របសម្រួល ផ្សព្វផ្សាយ និងអនុវត្តសកម្មភាពនានា តាមស្មារតីនៃសេចក្តីប្រកាស អាស៊ាន ស្តីពី "តួនាទីរបស់មុខងារសាធារណៈជាកាតាលីករសម្រាបការសម្រេចបាននូវចក្ខុវិស័យអាស៊ាន ឆ្នាំ២០២៥" ( ASEAN Declaration on the Role of Civil Service as a Catalyst for Achieving ASEAN Vision 2025 ) ជាមួយស្ថាប័នពាក់ព័ន្ធក្នុងស្រុក និងក្របខណ្ឌអាស៊ាន។

## ១១. ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ

**១**
- ការរៀបចំរចនាសម្ព័ន្ធរដ្ឋឡើងវិញ
- ការពង្រឹងសមត្ថភាពគ្រប់គ្រងរបស់បណ្តាក្រសួង ស្ថាប័ន
- ការកែទម្រង់មុខងារសធារណៈ
- ការអភិវឌ្ឍន៍ធនធានមនុស្ស
- ការពង្រឹងសមត្ថភាពគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង

**២**
- ការពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ
- ការរៀបចំសម្របសម្រួលរចនាសម្ព័ន្ធនិងការពង្រាយមន្ត្រីរាជការ
- ការធ្វើសនិទានកម្មមុខងារសាធារណៈនិងការអភិវឌ្ឍន៍ធនធានមនុស្ស

**៣**
- ការកែលម្អសេវាសាធារណៈ
- ការបង្កើតបៀវត្សនិងពង្រឹងការគ្រប់គ្រងនិយោជន៍
- ការអភិវឌ្ឍសមត្ថភាព
- ការជំរុញប្រើប្រាស់ប្រព័ន្ធបច្ចេកទេស

**៤**
- ពង្រឹងតម្លាភាពក្នុងដំណើរការនៃការបង្កើនគុណភាពសេវាសាធារណៈ
- ពង្រឹងគណនេយ្យភាពក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ
- អភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន
- ពង្រឹងការគ្រប់គ្រងធនធានមនុស្សនិងបៀវត្ស
- ពង្រឹងការគ្រប់គ្រងក្របខណ្ឌនិងការពង្រាយមន្ត្រីរាជការ

**៥**
- សេវាសាធារណៈប្រកបដោយគុណភាពភាពអាចជឿទុក ចិត្តបាន ភាពឆាប់រហ័សឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការមានភាពងាយស្រួលនិងមានការចូលរួមពីអ្នកប្រើប្រាស់សេវា
- ការគ្រប់គ្រងនិងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាពនិងភាពជឿទុកចិត្ត
- ប្រព័ន្ធបៀវត្សដែលធានាបាននូវសីលធម៌ បង្កើនផលិតភាពនិងប្រសិទ្ធភាពការងារព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ

១ — ១៩៩៣-១៩៩៨
ផ្សះផ្សា និងបង្រួបបង្រួមជាតិ

២ — ១៩៩៩-២០០៣
កសាងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ

៣ — ២០០៤-២០០៨
កំណែទម្រង់ស៊ីជម្រៅ

៤ — ២០០៩-២០១៣
បន្តកំណែទម្រង់ស៊ីជម្រៅ

៥ — ២០១៥-២០១៨
កំណែទម្រង់ស៊ីជម្រៅដើម្បីប្រសិទ្ធភាព

## ១២. ប្រវត្តិ និង ការងារបណ្តុះបណ្តាលផ្សេងរបស់សាលាភូមិន្ទរដ្ឋបាល

### ១២.១. អំពីសាលាភូមិន្ទរដ្ឋបាល

សាលាភូមិន្ទរដ្ឋបាល "ស.ភ.រ." ជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈដែលមានស្វ័យភាពផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុចំណុះក្រសួងមុខងារសាធារណៈបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ដោយព្រះរាជក្រម។ ចាប់តាំងពីការបង្កើតសាលាភូមិន្ទរដ្ឋបាលបានផ្លាស់ប្តូរឈ្មោះជាច្រើនលើកដោយសារកត្តាសង្គ្រាមផ្ទៃក្នុងនិងនយោបាយមិនច្បាស់លាស់បណ្តាលឱ្យឆ្លងកាត់ដំណាក់កាលសំខាន់ៗដូចជា៖

| | |
|---|---|
| ឆ្នាំ១៩១៤ | : សាលាក្រមការ |
| ឆ្នាំ១៩១៧ | : សាលារដ្ឋបាលនិងយុត្តិធម៌កម្ពុជា |
| ឆ្នាំ១៩៥៦-១៩៦៥ | : សាលាភូមិន្ទរដ្ឋបាល |
| ឆ្នាំ១៩៧២-១៩៧៥ | : សាលាជាតិរដ្ឋបាល |
| ឆ្នាំ១៩៨២-១៩៨៥ | : សាលាកម្មាភិបាលរដ្ឋបាលនិងនីតិសាស្ត្រ |
| ឆ្នាំ១៩៩៣-១៩៩៤ | : សាលាជាតិរដ្ឋបាលបន្ទាប់មកជាសាលាភូមិន្ទរដ្ឋបាល |
| ឆ្នាំ១៩៩៥-២០១៣ | : សាលាភូមិន្ទរដ្ឋបាលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី |
| ឆ្នាំ១៩១៣-បច្ចុប្បន្ន | : សាលាភូមិន្ទរដ្ឋបាលស្ថិតក្រោមក្រសួងមុខងារសាធារណៈ |

### ១២.២. ការបណ្តុះបណ្តាល

#### ក. ការបណ្តុះបណ្តាលដំបូង

ការបណ្តុះបណ្តាលដំបូង៖ ការជ្រើសរើសឱ្យចូលមកទទួលការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលត្រូវធ្វើឡើងដោយការប្រឡងប្រជែងសម្រាប់វគ្គបណ្តុះបណ្តាលដំបូងរបស់សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការតាមរយៈសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ រីឯសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលទទួលការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលតាមរយៈក្រសួង ស្ថាប័នបញ្ជូនមក យោងតាមព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល (មាត្រា ៨)។

- ការជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់៖ សិស្សឬមន្ត្រីរាជការ ត្រូវមានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ និងត្រូវទទួលការបណ្តុះបណ្តាលរយៈពេល២៤ខែ។សិស្សដែលបានរៀនចប់ដោយជោគជ័យត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការ និងផ្តល់៣ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលមន្ត្រីប្រឡងជាប់។
- ការជ្រើសរើសជាសិស្សមន្ត្រីក្រមការ៖ សិស្សឬមន្ត្រីរាជការ ត្រូវមានសញ្ញាបត្រឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតទុតិយភូមិបូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើនិងត្រូវទទួលការបណ្តុះបណ្តាលរយៈពេល១២ខែ។ សិស្សដែលបានរៀនចប់ដោយជោគជ័យ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការនិងផ្តល់២ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលមន្ត្រីប្រឡងជាប់ចំពោះអ្នកមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២ឆ្នាំនៃការសិក្សាបន្ថែមដោយមានសញ្ញាបត្រនិងផ្តល់៣ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលមន្ត្រីប្រឡងជាប់ចំពោះអ្នកមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ។
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មី៖ បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងឬ ក្នុងចំណោមនិស្សិត មានឋានៈជាសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយត្រូវទទួលការបណ្តុះ បណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល។ ការបណ្តុះបណ្តាលមានរយៈពេល១០៨ម៉ោង។

### ខ. ការបណ្តុះបណ្តាលបន្ត

ការបណ្តុះបណ្តាលបន្តរៀបចំធ្វើការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងមន្ត្រីសាធារណៈដទៃទៀតទៅតាមប្រភេទក្របខណ្ឌ និងមុខតំណែងគ្រប់គ្រង។ កម្មសិក្សាការីដែលទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យត្រូវបានដំឡើងថ្នាក់១(មួយ)ថ្នាក់ នៅក្នុងឋានន្តរស័ក្តិបច្ចុប្បន្នរបស់ខ្លួន។ ការបណ្តុះបណ្តាលបន្តមានដូចខាងក្រោម៖

- វិក្រឹត្យការមន្ត្រីជាន់ខ្ពស់: មន្ត្រីរាជការមុខតំណែងចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន ឬប្រហាក់ប្រហែល។ រយៈពេលបណ្តុះបណ្តាលយ៉ាងតិច៥៥០ម៉ោងឡើងទៅ។
- វិក្រឹត្យការមន្ត្រីគ្រប់គ្រង: មន្ត្រីរាជការស្ថិតក្នុងប្រភេទក្របខណ្ឌ ក ឬក្របខណ្ឌប្រហាក់ប្រហែលរដ្ឋបាល។ រយៈពេលបណ្តុះបណ្តាលយ៉ាងតិច៥៥០ម៉ោងឡើងទៅ។
- វិក្រឹត្យការមន្ត្រីមធ្យមៈ មន្ត្រីរាជការកាន់មុខតំណែង គ្រប់គ្រងពីប្រធានការិយាល័យថ្នាក់កណ្តាលអភិបាលរងក្រុងស្រុក ខណ្ឌ អនុប្រធានមន្ទីររាជធានីខេត្តឬមុខតំណែងប្រហាក់ប្រហែល។ រយៈពេលបណ្តុះបណ្តាលចាប់ពី៣៥០ម៉ោងដល់៤៥០ម៉ោង។
- វិក្រឹត្យការមន្ត្រីក្រមការៈមន្ត្រីរាជការស្ថិតក្នុងប្រភេទក្របខណ្ឌ ខ ឬក្របខណ្ឌប្រហាក់ប្រហែល។ រយៈពេលបណ្តុះបណ្តាលចាប់ពី៣៥០ម៉ោងដល់ ៤៥០ម៉ោង។

### គ. ការបណ្តុះបណ្តាលរយៈពេលខ្លី

ការបណ្តុះបណ្តាលរយៈពេលខ្លី លើជំនាញពាក់ព័ន្ធនឹងវិស័យសាធារណៈ ដើម្បីគាំទ្រដល់ការធ្វើបច្ចុប្បន្នភាពចំណេះដឹង និងបង្កើនសមត្ថភាពមន្ត្រីរាជការ មន្ត្រីសាធារណៈ និងមន្ត្រីផ្សេងទៀត ។ ការបណ្តុះបណ្តាលរយៈពេលខ្លីមានវគ្គ បណ្តុះបណ្តាលដូចជា៖

- វគ្គបណ្តុះបណ្តាលការបង្កើនសមត្ថភាពថ្នាក់ដឹកនាំជាស្ត្រី
- វគ្គបណ្តុះបណ្តាលការបង្កើនសមត្ថភាពថ្នាក់ដឹកនាំប្រធានអង្គភាព (អភិបាលខេត្ត និងអគ្គនាយក)
- វគ្គបណ្តុះបណ្តាលការកសាងសមត្ថភាពគណៈគ្រប់គ្រងគ្រឹះស្ថានអប់រំសាធារណៈ
- វគ្គបណ្តុះបណ្តាលគ្រប់គ្រងអង្គភាពសាធារណៈ
- វគ្គបណ្តុះបណ្តាលរដ្ឋបាលសាធារណៈ
- វគ្គបណ្តុះបណ្តាលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍
- វគ្គបណ្តុះបណ្តាលមន្ត្រីរាជការក្រសួងបរិស្ថាន

## ១២.៣. ទំនាក់ទំនងជាតិ និងអន្តរជាតិ

ដើម្បីជួយដល់ការធ្វើទំនើបកម្មចំណេះដឹងក្នុងរដ្ឋបាលសាធារណៈ សាលាភូមិន្ទរដ្ឋបាលបានធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិជាច្រើនមាន៖

### ក. ទំនាក់ទំនងជាតិ

សាលាភូមិន្ទរដ្ឋបាលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ៖ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងស្ថាប័នព្រឹទ្ធសភាលើកិច្ចប្រតិបត្តិការបណ្តុះបណ្តាលធនធានមនុស្ស ។

## ខ. ទំនាក់ទំនងអន្តរជាតិ

សាលាភូមិន្ទរដ្ឋបាលបានចុះកិច្ចព្រមព្រៀង សហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងស្ថាប័នបណ្តុះ-បណ្តាល អន្តរជាតិមួយចំនួន មានជាអាទិ៍ សាកលវិទ្យាល័យនៅសាធារណរដ្ឋកូរ៉េ សាកលវិទ្យាល័យការបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន សាលារដ្ឋបាលសាធារណរដ្ឋបារាំង វិទ្យាស្ថានជាតិសិក្សានយោបាយព្រះរាជា-ណាចក្រជប៉ុន សាកលវិទ្យាល័យប្រទេសអូស្ត្រាលី សាលារដ្ឋបាលសាធារណៈសឹង្ហបុរី សាលារដ្ឋបាលមូលដ្ឋាន សាធារណរដ្ឋប្រជាមានិតឡាវ ហើយសាលាភូមិន្ទរដ្ឋបាល ក៏ជាសមាជិកអង្គការតំបន់ភាគ ខាងកើត សម្រាប់ រដ្ឋបាលសាធារណៈ ។

## ១២.៤. កម្មវិធីផ្សេងៗ

### ក.កម្មវិធីផ្លាស់ប្តូរសិស្សមន្ត្រីនិងកម្មសិក្សាការី

កម្មវិធីផ្លាស់ប្តូរទស្សនកិច្ចសិក្សារបស់សិស្សមន្ត្រី និងកម្មសិក្សាការីនៃសាលាភូមិន្ទរដ្ឋបាលជាកម្មវិធីបណ្តុះ-បណ្តាលបង្កើនសក្តានុពលទំនាក់ទំនងអន្តរជាតិ ការរៀនសង្កេតដើម្បីបណ្តុះគំនិតច្នៃប្រឌិតសម្រាប់ជាតិ និង អន្តរជាតិ។

### ខ.កម្មវិធីកីឡា

កម្មវិធីកីឡារបស់សាលាភូមិន្ទរដ្ឋបាល ជាកម្មវិធីបណ្តុះបណ្តាល មានគោលបំណងដើម្បីបង្កើតមិត្តភាពសាម-គ្គីភាព ភាតរភាព និងសុខភាព ក៏ដូចជាការចូលរួមលើកកម្ពស់ក្នុងការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាផងដែរ។

### គ.កម្មវិធីសិល្បៈ

កម្មវិធីសិល្បៈរបស់សាលាភូមិន្ទរដ្ឋបាល ជាកម្មវិធីបណ្តុះបណ្តាល ស្មារតី សិស្សមន្ត្រី និងកម្មសិក្សាការីឱ្យកាន់តែស្គាល់នូវតម្លៃសម្បត្តិវប្បធម៌ជាតិ ហើយចេះស្រឡាញ់ គាំទ្រ និងថែរក្សាកេរដំណែលដូនតារបស់ខ្លួន។

### ឃ.កម្មវិធីសង្គម

កម្មវិធីសង្គមរបស់សាលាភូមិន្ទរដ្ឋបាល បង្កើតឡើងក្នុងគោលបំណងបណ្តុះស្មារតីជាក្រុម បណ្តុះគំនិតឱ្យគិតគូរចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជាធំ យល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួនចំពោះផលប្រយោជន៍រួម និង ពង្រឹងសមត្ថភាពផ្ទាល់ខ្លួនឱ្យបានរឹងមាំ ដើម្បីរួមចំណែកឱ្យបានកាន់តែសកម្មក្នុងការសម្រាលទុក្ខលំបាករបស់ប្រជា-ពលរដ្ឋ ដោយប្រកាន់ខ្ជាប់គុណសម្បត្តិ ៤យ៉ាងគឺៈ ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ។

### ង.កម្មវិធីសុខភាព និងអនាម័យ

កម្មវិធីសុខភាព និងអនាម័យរបស់សាលាភូមិន្ទរដ្ឋបាល ជាកម្មវិធីបណ្តុះបណ្តាលឱ្យមានទម្លាប់ទទួលខុសត្រូវ សុខភាព គិតគូរពីសុខភាព ចូលរួមលើកកម្ពស់អនាម័យ និងបរិស្ថាន ។



ប្រព័ន្ធព័ត៌មានមន្ត្រីរាជការស៊ីវិល
ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE
ព័ត៌មានការសិក្សា
ព័ត៌មានទូទៅ
ឈ្មោះ៖
ឈ្មោះឡាតាំង៖
អត្តលេខមន្ត្រី៖
ភេទ៖
ថ្ងៃខែឆ្នាំកំណើត៖
បច្ចុប្បន្នបម្រើការងារនៅក្រសួង ស្ថាប័ន៖ មុខងារសាធារណៈ
ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់៖
មុខតំណែង៖
ថ្ងៃចូលបំរើការងាររដ្ឋ៖
ទីកន្លែងបំរើការងាររដ្ឋ៖ ថ្នាក់កណ្ដាល
ព័ត៌មានបៀវត្សប្រចាំ ខែ
ធ្នូ
ឆ្នាំ
2018
QR Code ខ្ញុំ
ប្រវត្តិសិក្សា
• មន្ត្រីអាចមើលព័ត៌មានសិក្សា
• មន្ត្រីអាចបន្ថែមប្រវត្តិសិក្សា
• មន្ត្រីអាចកែប្រែប្រវត្តិសិក្សា
ព័ត៌មានទូទៅ
• មន្ត្រីអាចមើលព័ត៌មានផ្ទាល់ខ្លួន
• មន្ត្រីអាចមើលបៀវត្សប្រចាំខែ
• មន្ត្រីអាចមើលព័ត៌មានគ្រួសារ
QR កូដ
• មើលព័ត៌មានទំនាក់ទំនង
• ចែករំលែកព័ត៌មានទំនាក់ទំនង
Available on the iPhone
App Store
GET IT ON
Google Play

# "កែទម្រង់រស់ មិនកែទម្រង់ស្លាប់"
# យើងចូលរួមអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ




គេហទំព័រក្រសួង: www.mcs.gov.kh
Facebook: www.facebook.com/civilservicecambodia
អាសយដ្ឋាន៖ ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា